## ២.ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០១

**ប្រកាសលេខ ៦៥ ផក.ប្រក**

**ស្តីពី**

**ការប្រើប្រាស់កំរងទិន្នន័យមូលដ្ឋានឃុំ-សង្កាត់**

* * *

**រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ
- បានឃើញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរផែនការខេត្ត-ក្រុងលេខ ២៣២ផក.ប្រក ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០០

យោងតាមតម្រូវការចាំបាច់

**សំរេច**

**ប្រការ ១ :** គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវជួយមន្ត្រីដឹកនាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ នៅខេត្ត ក្រុងរបស់ខ្លួន ក្នុងការប្រមូលចងក្រងទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ ។

**ប្រការ ២ :** ក្នុងការជួយមន្ត្រីដឹកនាំមូលដ្ឋានភូមិ ឃុំ-សង្កាត់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង ... សំណួរ តាមគំរូភ្ជាប់ម...

ឆ្នាំ ..................................

**ប្រការ ៣ :** គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវប្រើប្រាស់ឯកសារណែនាំអំពីខ្លឹមសារសំណួរក្នុងកំរងសំណួរទិន្នន័យមូលដ្ឋានភូមិ-ឃុំ-សង្កាត់ ដែលរៀបចំឡើងដោយក្រសួងផែនការ ដូចមានភ្ជាប់មកជាមួយប្រកាសនេះ សំរាប់ធ្វើការប្រមូលយកពត៌មានទិន្នន័យមូលដ្ឋានពីភូមិ ឃុំ-សង្កាត់ ។

**ប្រការ ៤ :** យោងតាមតំរូវការពត៌មានសំរាប់ការងារអភិវឌ្ឍន៍ខេត្ត-ក្រុងរបស់ខ្លួនផ្ទាល់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង អាចធ្វើការប្រមូលពត៌មានទិន្នន័យភូមិ ឃុំ-សង្កាត់ បន្ថែមលើ ៧៧សំណួរ ។ សំណួរដែលបន្ថែមនោះ រក្សាទុកត្រឹមថ្នាក់ខេត្ត-ក្រុង ដោយពុំបាច់ផ្ញើមកក្រសួងផែនការឡើយ ។

**ប្រការ ៥ :** ការប្រមូល និងចងក្រងកំរងទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ គ្រប់មន្ទីរផែនការខេត្ត-ក្រុង ត្រូវអនុវត្តន៍តាមជំហ៊ានការងារ និងកាលបរិច្ឆេទដែលបានកំណត់ និងផ្ញើកំរងទិន្នន័យមូលដ្ឋាននោះ មកអគ្គនាយកដ្ឋានផែនការផ្នែកកម្មវិធីសិលា ដើម្បីចាត់ចែងការងារបន្ត ។

**ប្រការ ៦ :** គំរូកំរងទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ ដែលបានប្រើតាមរយៈប្រកាសលេខ ២៦ ផក ។ ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់ក្រសួងផែនការ ត្រូវចាត់ទុកនិរាករណ៍ ។

**ប្រការ ៧ :** អគ្គនាយកផែនការ នាយវិទ្យាស្ថានជាតិស្ថិតិ អគ្គាធិការនៃក្រសួងផែនការ គ្រប់ប្រធាននាយកដ្ឋានជំនាញក្រោមឱវាទក្រសួងផែនការ គ្រប់ប្រធានមន្ទីរផែនការខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះឱ្យបានល្អប្រសើរតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ឆាយ ថន**

៚

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * *

# សៀវភៅនិន្នន័យភូមិ

ភូមិ : .......................................................លេខកូដភូមិសាស្ត្រ : .......................................................

ឃុំ : .......................................................ស្រុក : .......................................................

ខេត្ត : .......................................................

ឆ្នាំ ..................................

## បញ្ជីសំណួរ

| លេខរ | សំណួរ | ចំនួន |
|---|---|---|
| ១ | ចំនួនគ្រួសារសរុបក្នុងភូមិ | |
| ២ | ចំនួនមនុស្សស្រីសរុប | |
| ៣ | ចំនួនមនុស្សប្រុសសរុប | |
| ៤ | ចំនួនក្មេងស្រី អាយុពី ០ ដល់ ៤ ឆ្នាំ ( ក្រោម ៥ឆ្នាំ) | |
| ៥ | ចំនួនក្មេងប្រុស អាយុពី ០ ដល់ ៤ ឆ្នាំ ( ក្រោម ៥ឆ្នាំ) | |
| ៦ | ចំនួនក្មេងស្រី អាយុពី ៥ ដល់ ១៤ ឆ្នាំ | |
| ៧ | ចំនួនក្មេងប្រុស អាយុពី ៥ ដល់ ១៤ឆ្នាំ | |
| ៨ | ចំនួនស្ត្រីអាយុពី ៦៥ ឆ្នាំឡើង | |
| ៩ | ចំនួនបុរសអាយុពី ៦៥ឆ្នាំឡើង | |
| ១០ | ចំនួនក្មេងស្រីអាយុពី ៥ ដល់ ១៤ ឆ្នាំ ដែលមានចូលរៀន | |
| ១១ | ចំនួនក្មេងប្រុសអាយុពី ៥ ដល់ ១៤ ឆ្នាំ ដែលបានចូលរៀន | |
| ១២ | ចំនួនអនក្ខរជនភេទស្រី ដែលមានអាយុលើសពី ១៥ ឆ្នាំ | |
| ១៣ | ចំនួនអនក្ខរជនភេទប្រុសដែលមានអាយុលើសពី ១៥ ឆ្នាំ | |
| ១៤ | ចំនួនមនុស្សស្រីបាត់បង់សមត្ថភាពពលកម្ម | |
| ១៥ | ចំនួនមនុស្សប្រុសបាត់បង់សមត្ថភាពពលកម្ម | |
| ១៦ | ចំនួនកុមារកំព្រាអាយុតិចជាង ១៥ ឆ្នាំ | |
| ១៧ | ចំនួនកុមារាកំព្រាអាយុតិចជាង ១៥ ឆ្នាំ | |
| ១៨ | ចំនួនគ្រួសារដែលមានមេគ្រួសារជាស្ត្រី | |
| ១៩ | ចំនួនគ្រួសារប្រកបរបរដាំដុះជាចំណូលសំខាន់ | |
| ២០ | ចំនួនគ្រួសារកសិករដាំដុះលើដីផ្ទាល់ខ្លួន | |
| | **គេហដ្ឋាន** | **ចំនួន** |
| ២១ | ចំនួនផ្ទះថ្ម | |

| | | |
|---|---|---|
| ២២ | ចំនួនផ្ទះឈើ | |
| ២៣ | ចំនួនផ្ទះស្លឹក | |
| ២៤ | ចំនួនផ្ទះដែលមានអគ្គិសនី ( ១១០.២២០វ៉ុល) | |
| | **ការអប់រំ** | **ចំនួន** |
| ២៥ | ចំនួនបន្ទប់សាលាបឋមសិក្សានៅក្នុងភូមិ | |
| ២៦ | ចំនួនបន្ទប់សាលាមធ្យមសិក្សានៅក្នុងភូមិ | |
| ២៧ | ចំនួនគ្រូបឋមសិក្សា | |
| ២៨ | ចំនួនគ្រូមធ្យមសិក្សា | |
| ២៩ | ចំនួនថ្នាក់អក្ខរកម្ម | |
| ៣០ | ចំនួនបន្ទប់រៀននៃសាលាមត្តេយ្យសិក្សា | |
| | **សុខភាព** | **ចំនួន** |
| ៣១ | ចំនួនភ្នាក់ងារសុខាភិបាលនៅក្នុងភូមិ | |
| ៣២ | ចំនួនគ្រូខ្មែរដែលមានក្នុងភូមិ | |
| ៣៣ | ចំនួនឆ្មបបុរាណដែលមានក្នុងភូមិ | |
| ៣៤ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមាននៅក្នុងភូមិ | |
| ៣៥ | ចំនួនកុមារអាយុពី ០-៥ឆ្នាំ ស្លាប់រយៈពេល ១២ខែមុន | |
| ៣៦ | ចំនួនស្ត្រីស្លាប់បន្ទាប់ពីសំរាលកូនបាន ២៨ថ្ងៃ ( គិត១២ខែកន្លងមក) | |
| | **ទឹកស្អាត និងអនាម័យ** | **ចំនួន** |
| ៣៧ | ចំនួនអណ្តូងលូដែលប្រើបានគ្រប់រដូវ | |
| ៣៨ | ចំនួនអណ្តូងជីជីកដោយដៃដែលប្រើបានគ្រប់រដូវ | |
| ៣៩ | ចំនួនអណ្តូងស្នប់ដែលប្រើបានគ្រប់រដូវ | |
| ៤០ | ចំនួនស្រះទឹកហូបដែលអ្នកភូមិប្រើប្រាស់ | |
| ៤១ | ចំនួនបង្គន់អនាម័យដែលប្រើការកើត | |

| | ដឹកជញ្ជូន | ចំនួន |
|---|---|---|
| ៤២ | ចំនួនម៉ូតូ | |
| ៤៣ | ចំនួនត្រាក់ទ័រ គោយន្ត រថយន្ត | |
| ៤៤ | ចំនួនរទេះគោ និងរទេះសេះ | |
| ៤៥ | ចំនួនកង់ | |
| ៤៦ | ចំនួនទូកចែវ/អុំ | |
| ៤៧ | ចំនួនទូកម៉ាស៊ីន/កាណូត | |
| ៤៨ | ចំងាយពីភូមិទៅផ្សារដែលនៅជិតបំផុត (គិតជាគីឡូម៉ែត្រ) | |
| ៤៩ | ចំងាយពីភូមិទៅផ្លូវដែលនៅជិតបំផុតដែលអាចបើកឡានចេញចូលពេញ ១ឆ្នាំ (គិតជាគីឡូម៉ែត្រ) | |
| ៥០ | ចំងាយពីភូមិទៅសាលាមធ្យមសិក្សាជិតបំផុត (គិតជាគ.ម) | |
| ៥១ | ចំងាយពីភូមិទៅមណ្ឌលសុខភាពឃុំជិតបំផុត (គិតជាគ.ម) | |
| | **ធនធានកសិកម្ម** | **ចំនួន** |
| ៥២ | ផ្ទៃដីស្រែវស្សា (គិតជាហិកតា) | |
| ៥៣ | ផ្ទៃដីស្រែវស្សាបង្កើនរដូវ (គិតជាហិកតា) | |
| ៥៤ | ផ្ទៃដីស្រែបាំងប្រដេញទឹក (គិតជាហិកតា) | |
| ៥៥ | ផ្ទៃដីស្រែប្រាំងស្រោចស្រព (គិតជាហិកតា) | |
| ៥៦ | ផ្ទៃដីស្រូវចំការ (គិតជាហិកតា) | |
| ៥៧ | ផ្ទៃដីដាំដុះដំណាំផ្សេងៗទៀត (គិតជាហិកតា) | |
| ៥៨ | ផ្ទៃដីមានមីន (គិតជាហិកតា) | |
| ៥៩ | ចំនួនអណ្តូងទឹកស្រោចស្រព | |
| | **ផលិតផលក្នុងឆ្នាំ** | **ចំនួន** |
| ៦០ | ផលិតផលស្រូវសរុបក្នុងរយៈពេល ១២ខែ កន្លងមក (គិតជាតោន) | |
| ៦១ | ផលិតផលពោតសរុបក្នុងរយៈពេល ១២ខែ កន្លងមក (គិតជាតោន) | |

| | ការចិញ្ចឹមសត្វ | ចំនួន |
|---|---|---|
| ៦២ | ចំនួនគោ-ក្របី ដែលមិនមែនជាកំលាំងអូសទាញមានក្នុងភូមិ | |
| ៦៣ | ចំនួនគោ-ក្របីដែលជាកំលាំងអូសទាញមានក្នុងភូមិ | |
| ៦៤ | ជ្រូកមាននៅក្នុងភូមិ | |
| ៦៥ | ចំនួនភ្នាក់ងារពេទ្យសត្វនៅក្នុងភូមិ | |
| | **សេដ្ឋកិច្ចជនបទ** | **ចំនួន** |
| ៦៦ | ចំនួនកន្លែងផ្តល់សេវាកម្មកសិកម្ម | |
| ៦៧ | ចំនួនកន្លែងផលិតកម្មកសិកម្មជនបទ | |
| ៦៨ | ចំនួនកន្លែងផលិតកម្មសិប្បកម្មជនបទ | |
| ៦៩ | ចំនួនសេវាកម្ម និងតូបលក់ទំនិញនានា | |
| | **ទ្រព្យសម្បត្តិគ្រួសារ** | **ចំនួន** |
| ៧០ | ចំនួនទូរទស្សន៍ | |
| | **ការចាកចេញពីភូមិទៅរកការធ្វើ** | **ចំនួន** |
| ៧១ | ចំនួនមនុស្សស្រីចាកចេញពីភូមិទៅរកការងារធ្វើ | |
| ៧២ | ចំនួនមនុស្សប្រុសចាកចេញពីភូមិទៅរកការងារធ្វើ | |
| | **ការរៀបចំតាមសហគមណ៍ជនបទ** | **ចំនួន** |
| ៧៣ | ចំនួនក្រុមឥណទានប្រាក់ | |
| ៧៤ | ចំនួនក្រុមធនាគារសត្វ | |
| ៧៥ | ចំនួនក្រុមធនាគារស្រូវ | |
| ៧៦ | ចំនួនក្រុមប្រើប្រាស់ទឹកហូប | |
| ៧៧ | ចំនួនក្រុមកសិករប្រើប្រាស់ទឹកស្រោចស្រព | |

សំគាល់ :

សំណួរទាំងប៉ុន្មានខាងលើនេះ មិនអនុញ្ញាតអោយធ្វើការផ្លាស់ប្តូរលេខរៀង ឬ ខ្លឹមសារ បើមាន ករណីចាំបាច់ ខេត្តអាចបន្ថែមសំណួរនៅក្នុងតារាងបន្ទាប់ ។

បើគ្មានចំនួនតួលេខស្ថិតិទេ ត្រូវបំពេញចំលើយសូន្យ តែបើមានដែរ តែប្រធានភូមិភ្លេចឆ្លើយ ឬ ពុំ ច្បាស់លាស់ សូមកុំបំពេញលេខសូន្យជំនួសប្រធានភូមិអោយសោះ សូមទុកចំហរចោល ឬ ធ្វើការបញ្ជាក់ជា មួយប្រធានភូមិម្តងទៀត ។

ប្រធានភូមិ មេឃុំ និងមន្ត្រីផែនការស្រុក ត្រូវចុះហត្ថលេខា និងឈ្មោះលើខ្នងសៀវភៅនេះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាផ្លូវការចំពោះតួលេខស្ថិតិដែលខ្លួនបានបំពេញ ។

ខ្នាតចំងាយត្រូវគិតជាគីឡូម៉ែត្រ ខ្នាតផ្ទៃដីត្រូវគិតជាហិកតា ផលិតផលសរុបត្រូវគិតជាតោន ដើម្បី អោយមានការឯកភាពទូទាំងប្រទេស ។

**សំណួរបន្ថែមតាមខេត្តនីមួយៗ**

| លេខរ | សំណួរ | ចំនួន |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

# សេចក្តីណែនាំខ្លឹមសារសំណួរ

ក្នុង

# សៀវភៅទិន្នន័យភូមិ

ក្រសួងផែនការ

២០០១

## ជំពូក ១ : ស្ថិតិភូមិ

**១- ចំនួនគ្រួសារសរុបក្នុងភូមិ :** ជាចំនួនគ្រួសារដែលរស់នៅអចិន្ត្រៃយ៍ក្នុងភូមិ ដោយមិនគិតពីគ្រួសារដែលស្នាក់នៅបណ្ដោះអាសន្ន ហើយនិងត្រូវវិលត្រឡប់ទៅភូមិកំណើតវិញក្នុងពេលឆាប់ៗ ឡើយ ។

**គ្រួសារ :** គ្រួសារមួយគឺជាមនុស្សមួយក្រុម ដែលរស់នៅជាមួយគ្នា ហើយបរិភោគបាយដែលចេញពីចង្ក្រានរួម ហើយចាយវាយថវិការួមគ្នា តែចំណូលបានមកផ្សេងៗពីគ្នា ។

**២- ចំនួនមនុស្សស្រីសរុប :** ចំនួនស្ត្រីសរុបរស់នៅក្នុងភូមិ ដោយមិនគិតអាយុទាំងចាស់ ទាំងក្មេង ។

**៣- ចំនួនមនុស្សប្រុសសរុប :** ចំនួនបុរសសរុបរស់នៅក្នុងភូមិ ដោយមិនគិតអាយុទាំងចាស់ទាំងក្មេង ។

**- ចំនួនក្មេងស្រីអាយុពី ០ ដល់ ៤ឆ្នាំ (ក្រោម៥ឆ្នាំ ) :** ចំនួនក្មេងស្រីទាំងអស់ អាយុក្រោម ៥ឆ្នាំ គិតត្រឹមថ្ងៃស្រង់ស្ថិតិ ។

**៥- ចំនួនក្មេងប្រុសអាយុពី ០ ដល់ ៤ឆ្នាំ (ក្រោម៥ឆ្នាំ) :** ក្មេងប្រុសទាំងអស់អាយុក្រោម ៥ឆ្នាំ គិតត្រឹមថ្ងៃស្រង់ស្ថិតិ ។

**៦- ចំនួនក្មេងស្រីពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ :** គឺជាចំនួនក្មេងស្រីដែលមានអាយុពី៥ឆ្នាំ រហូតដល់ ១៤ឆ្នាំ នៅក្នុងភូមិ ( ក្រោម១៥ឆ្នាំ) ។

**៧- ចំនួនក្មេងប្រុសពី៥ឆ្នាំ ដល់១៤ឆ្នាំ :** ជាចំនួនក្មេងប្រុសដែលមានអាយុពី ៥ឆ្នាំពេញ រហូតដល់ ១៤ឆ្នាំ ។

**៨- ចំនួនស្ត្រីអាយុពី ៦៥ឆ្នាំឡើង :** ជាចំនួនស្ត្រីអាយុពី ៦៥ឆ្នាំឡើងទៅនៅក្នុងភូមិ ។

**៩- ចំនួនបុរសអាយុពី ៦៥ឆ្នាំឡើង :** ជាចំនួនមនុស្សប្រុសអាយុពី ៦៥ឆ្នាំឡើងទៅនៅក្នុងភូមិ ។

**១០- ចំនួនក្មេងស្រីពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន :** ជាចំនួនក្មេងស្រីចាប់ពីអាយុ ៥ឆ្នាំពេញ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន (ពីមត្តេយ្យឡើងទៅ) ។

**១១- ចំនួនក្មេងប្រុសពី ៥ឆ្នាំ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន :** ជាចំនួនក្មេងប្រុសចាប់ពីអាយុ ៥ឆ្នាំពេញ ដល់ ១៤ឆ្នាំ ដែលបានចូលរៀន (ពីមត្តេយ្យឡើងទៅ) ។

១២. **ចំនួនអនក្ខរជនភេទស្រីដែលមានអាយុពី១៥ឆ្នាំឡើង** : សំណួរនេះត្រូវវាស់ភាពមិនចេះអក្សរឱ្យបានដូចៗគ្នាគ្រប់ខេត្តទូទាំងប្រទេស ។ ស្ត្រីមិនចេះអក្សរ ដែលស្រង់គឺជាចំនួនមនុស្សស្រីចាប់ពីអាយុ១៥ឆ្នាំឡើង ដែលមិនអាចអានអត្ថបទបានត្រឹមត្រូវពី៥ទៅ៦បន្ទាត់ និងសរសេរអក្សរមិន បានពី ៣ ទៅ ៥បន្ទាត់ ។

១៣. **ចំនួនអនក្ខរជនភេទប្រុសដែលមានអាយុលើសពី ១៥ឆ្នាំ** : ដូចគ្នានិងសំណួរខាងលើដែរ ដោយ គ្រាន់តែប្តូរមកជាចំនួនមនុស្សប្រុសវិញ ។

១៤. **ចំនួនស្រីបាត់បង់សមត្ថភាពពលកម្ម** : សំណួរនេះសំដៅយកស្ត្រីណាដែលបាត់បង់អវៈយវៈសរីរាង្គ ឬ វិញ្ញាណណាមួយដែលមានពីកំណើត ឬ ដោយសារជំងឺ សង្គ្រាម ឬ គ្រោះថ្នាក់ផ្សេងៗទៀត ។ ទោះបីមានមនុស្សពិការខ្លះមានលទ្ធភាពជួយធ្វើការគ្រួសារខ្លះក៏ដោយ ក៏ត្រូវរាប់បញ្ចូល ដែរ តែចំពោះមនុស្សចាស់អាយុចាប់ពី ៦៥ឆ្នាំឡើងទៅ មិនត្រូវរាប់បញ្ចូលទេ ។

១៥. **ចំនួនមនុស្សប្រុសបាត់បង់សមត្ថភាពពលកម្ម** : (ដូចសំណួរទី ១៤) គ្រាន់តែប្តូរពីស្រីមកប្រុសប៉ុណ្ណោះ ។

១៦. **ចំនួនកុមារីកំព្រាអាយុតិចជាង ១៥ឆ្នាំ** : គឺជាចំនួនកុមារកំព្រា ភេទស្រី មានសរុបក្នុងភូមិ ។ កុមារកំព្រា គឺជាកុមារដែលមានអាយុតិចជាង ១៥ឆ្នាំ ហើយបាត់បង់ទាំងឪពុក ទាំងម្តាយ ដោយស្លាប់ ឬ បាត់ដំណឹងយូរមកហើយគ្មានអ្នកថែរក្សាគ្រប់គ្រង ។ កូនចិញ្ចឹមមិនរាប់បញ្ចូលថាជាកុមារកំព្រាឡើយ ។

១៧. **ចំនួនកុមារ កំព្រាអាយុតិចជាង១៥ឆ្នាំ** : (ដូចសំណួរទី១៦ គ្រាន់តែប្តូរពីក្មេងស្រីមកក្មេងប្រុស) ។

១៨. **ចំនួនគ្រួសារដែលមានមេគ្រួសារជាស្រី** : មេគ្រួសារ គឺជាមនុស្សមួយរូប ដែលគេទទួលស្គាល់ថាជាមេនៅក្នុងគ្រួសារ ។ ចំពោះមេគ្រួសារជាស្ត្រីនេះ គឺមានស្ត្រីជាអ្នកទទួលខុសត្រូវចាត់ចែងក្នុងគ្រួសារ ហើយធ្វើសេចក្តីសំរេចកិច្ចការនានាក្នុងនាមគ្រួសារ ។

១៩. **ចំនួនគ្រួសារដែលប្រកបរបរដាំដុះជាចំណូលសំខាន់** : គឺជាចំនួនសរុបគ្រួសារកសិករក្នុងភូមិដែលបានប្រកាន់យកការដាំដំណាំ ឬ ធ្វើស្រែចំការជាប្រភពចំណូលសំខាន់សំរាប់ចិញ្ចឹមគ្រួសារ ដោយមិនគិតថា គ្រួសារនោះមានមុខរបរបន្ទាប់បន្សំច្រើនផ្សេងទៀត ឬ គ្មាននោះទេ ។

**២០. គ្រួសារកសិករដាំដុះលើដីផ្ទាល់ខ្លួន :** ចេញពីចំនួនគ្រួសារក្នុងសំណួរខាងលើ សំរាប់គ្រួសារណា ដែលធ្វើស្រែចំការតែលើដីផ្ទាល់ខ្លួនប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលគ្រួសារដែលខ្លួនឯងគ្មានដីដាំដុះ សោះ ហើយទៅជួលគេមកធ្វើការដាំដុះ ។

## ជំពូក ២ : គេហដ្ឋាន

**២១. ចំនួនផ្ទះថ្ម :** គឺជាផ្ទះដែលសង់ឡើងអំពីថ្ម ឬ ឥដ្ឋ យើងគិតបញ្ចូលជាផ្ទះថ្មដែរ ប្រសិនបើផ្ទះនោះខាង ក្រោមថ្ម ខាងលើឈើ ដោយមិនគិតដំបូល ។

**២២. ចំនួនផ្ទះឈើ :** គឺជាចំនួនផ្ទះដែលសង់ឡើងដោយសសរឈើ ដែលមានជញ្ជាំងបាំងធ្វើអំពីក្តារ ទោះ មានរៀបថ្មជាបន្ទប់ខាងក្រោមបន្តិចបន្តួច ក៏រាប់ជាផ្ទះឈើដែរ ដោយមិនគិតពីដំបូល ។

**. ចំនួនផ្ទះស្លឹក :** គឺជាចំនួនផ្ទះដែលសង់ឡើងដោយសសរឈើ តែជញ្ជាំងស្លឹក ដំបូលស្លឹក ទោះជាផ្ទះ មានជញ្ជាំងបាំងអំពីក្តារបន្តិចបន្តួច ក៏គិតជាផ្ទះស្លឹកដែរ ។ គិតបញ្ចូលទាំងផ្ទះបណ្តែតទឹក និងយក ទូកធ្វើ ជាផ្ទះនៅជាប្រចាំផងដែរ ប្រសិនបើគ្រួសារគាត់ត្រូវបានរាប់បញ្ចូលជាគ្រួសារដែលរស់នៅ អចិន្ត្រៃ ក្នុងភូមិដូចក្នុងសំណួរទីមួយខាងលើដែរ ។

**២៤. ចំនួនផ្ទះដែលមានអគ្គិសនី(១១០.២២០វុល) :** ជាចំនួនសរុបនៃផ្ទះទាំងអស់ដែលប្រើប្រាស់ ចរន្តអគ្គិសនី ១១០-២២០វុល ទោះជាអគ្គិសនីរដ្ឋ ឬ ឯកជនក៏ដោយ ។

## [illegible]

**២៥. ចំនួនបន្ទប់សាលាបឋមសិក្សាសរុបនៅក្នុងភូមិ :** ចំនួនបន្ទប់រៀនបឋមសិក្សាកំពុងប្រើប្រាស់ មានទីតាំងនៅក្នុងភូមិ ។

**២៦. ចំនួនបន្ទប់សាលាមធ្យមសិក្សាសរុបនៅក្នុងភូមិ :** ចំនួនបន្ទប់រៀនមធ្យមសិក្សាកំពុងប្រើប្រាស់ មានទីតាំងនៅក្នុងភូមិ ។

**ៗ. ចំនួនគ្រូបឋមសិក្សា :** ចំនួនគ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាបឋមសិក្សាក្នុងភូមិ គិតទាំង គ្រូជាប់កិច្ចសន្យាផងដែរ ប៉ុន្តែពុំរាប់បុគ្គលិកការិយាល័យទេ ។ បើគ្រូនោះមិនបានបង្រៀននៅ សាលានៅក្នុងភូមិ គឺមិនត្រូវរាប់ទេ ព្រោះនាំអោយត្រួតតួលេខដែលភូមិមួយទៀតបានរាប់បញ្ចូល រួចទៅហើយ ។

**២៨.  ចំនួនបន្ទប់មធ្យមសិក្សា** : ចំនួនគ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាមធ្យមសិក្សាក្នុងភូមិ គិត ទាំងគ្រូជាប់កិច្ចសន្យាផងដែរ ប៉ុន្តែពុំរាប់បុគ្គលិកការិយាល័យទេ។ ដូចគ្នានិងសំណួរខាងលើ ដើម្បីជៀសវាងការចុះត្រួតគ្នាលេខ។

**២៩.ចំនួនថ្នាក់អក្ខរកម្ម** : ចំនួនថ្នាក់បង្រៀនអក្សរដល់មនុស្សពេញវ័យ ឬ មនុស្សចាស់ ដែលមាននៅក្នុងភូមិ ទោះជាអង្គការ ឬ ស្ថាប័នណាបង្កើតក៏ដោយ។

**៣០.  ចំនួនបន្ទប់រៀនមត្តេយ្យសិក្សា** : ចំនួនបន្ទប់មត្តេយ្យសិក្សាមានក្នុងភូមិ។

## ជំពូក ៤ : សុខភាព

**៣១.ចំនួនភ្នាក់ងារសុខាភិបាលនៅក្នុងភូមិ** : គឺជាចំនួនជនស្ម័គ្រចិត្តនៅក្នុងភូមិ ដែលបានបណ្ដុះបណ្ដាលដោយសុខាភិបាលខេត្ត-ក្រុង ខាងផ្នែកអប់រំសុខភាពបឋមនៅក្នុងភូមិ។ បើភ្នាក់ងារនេះមកពីភូមិដទៃ មិនត្រូវរាប់បញ្ចូលទេ ព្រោះវាអាចត្រួតគ្នាលេខគ្នា ។

**៣២.ចំនួនគ្រូខ្មែរដែលមានក្នុងភូមិ** : ចំនួនគ្រូខ្មែរដែលព្យាបាលជម្ងឺដោយផ្សំថ្នាំតាមបែបបុរាណ ពី ឫស មើម សំបក ស្លឹករុក្ខជាតិ មាននៅក្នុងភូមិទាំងអស់ ។

**៣៣.ចំនួនឆ្មបបុរាណដែលមានក្នុងភូមិ** : គឺជាឆ្មបពុំបានឆ្លងកាត់ការបណ្ដុះបណ្ដាលពីសាលាឆ្មបរដ្ឋ តែបានជួយបង្កើតកូននៅពេលអ្នកភូមិត្រូវការ។

**៣៤.ចំនួនពេទ្យឆ្មបដែលបានបណ្ដុះបណ្ដាលមាននៅក្នុងភូមិ** : គឺចំនួនឆ្មបដែលបានឆ្លងកាត់ការបណ្ដុះបណ្ដាលដោយសុខាភិបាលខេត្ត ឬ ក្រុង ។

**៣៥.  ចំនួនកុមារអាយុ ០ ដល់ ៥ឆ្នាំ ស្លាប់ក្នុងរយៈពេល ១២ខែកន្លងមក** :

កុមារទាំងពីរភេទដែល បានស្លាប់ពីអាយុ ០ ដល់ ៥ឆ្នាំ នៅក្នុងរយៈ ១២ខែកន្លងមក។

**៣៦.  ចំនួនស្ត្រីស្លាប់បន្ទាប់ពីសំរាលកូនបាន ២៨ថ្ងៃ (គិត១២ខែកន្លងមក)** :

ស្ត្រីឆ្លងទន្លេស្លាប់ គឺគិតតែក្នុងរយៈពេល ២៨ថ្ងៃ ក្រោយពីឆ្លងទន្លេប៉ុណ្ណោះ។ បើហួសពី ២៨ថ្ងៃ គឺមានន័យថាស្លាប់ ក្នុងករណីផ្សេងៗ មិនអាចរាប់បញ្ចូលបានទេ។

**៣៧. ចំនួនអណ្តូងល្អដែលប្រើប្រាស់បានគ្រប់រដូវ** : គឺអណ្តូងដែលជីកដាក់លូតាមក្បួនអនាម័យដែលប្រើបានគ្រប់រដូវ ( ឬមានទឹកគ្រប់រដូវ) ។

**៣៨. ចំនួនអណ្តូងជីកដោយដៃដែលប្រើបានគ្រប់រដូវ** : គឺអណ្តូងដែលជីកហើយមិនដាក់ខ្នោះ ( លូ ) ដែលអាចប្រើបានគ្រប់រដូវ ( មានទឹកគ្រប់រដូវ) ។

**៣៩. ចំនួនអណ្តូងស្នប់ដែលប្រើបានគ្រប់រដូវ** : គឺអណ្តូងអង្គការនានា ឬ ស្ថាប័នផ្សេងៗធ្វើជូនដែលមាននៅក្នុងភូមិ ឬ ប្រជាជនជួលគេជីកប្រើប្រាស់ខ្លួនឯង។

**៤០. ចំនួនស្រះទឹកហូបដែលអ្នកភូមិប្រើប្រាស់** : ស្រះទឹកសំរាប់ហូបរបស់ប្រជាជនក្នុងភូមិដែលរួមកំលាំងគ្នាជីកជាស្រះធំៗ ឬ ផ្តល់ដោយអង្គការនានា ឧទាហរណ៍ : ដូចជា ស្រះតាមវត្ត ។

**៤១. ចំនួនបង្គន់អនាម័យដែលប្រើការកើត** : ចំនួនបង្គន់តាមលំនៅដ្ឋាន និងបង្គន់សាធារណៈដែលមានបិទបាំងជិតល្អ ហើយកំពុងប្រើប្រាស់សព្វថ្ងៃ ។

**៤២. ចំនួនម៉ូតូ** : គឺជាម៉ូតូគ្រប់ប្រភេទដែលមាននៅក្នុងភូមិ។ ទោះជាម៉ូតូរឺម៉កក៏ត្រូវចុះបញ្ចូលក្នុងសំណួរទី៤២ នេះដែរ ។

**៤៣. ចំនួនត្រាក់ទ័រ/គោយន្ត/រថយន្ត** : ចំនួនត្រាក់ទ័រ គោយន្ត និងរថយន្ត សរុបរួម ដែលកំពុងប្រើប្រាស់សព្វថ្ងៃនៅក្នុងភូមិ ។

**៤៤. ចំនួនរទេះសេះ និងចំនួនរទេះគោ** : ចំនួនសរុបនៃរទេះសេះ និងរទេះគោក្របីគ្រប់ប្រភេទ កំពុងប្រើប្រាស់នៅក្នុងភូមិ។ រទេះសេះ គឺជារទេះគ្រប់ប្រភេទដែលអូសដោយកំលាំងសេះ។ រទេះ គោ-ក្របី គឺជារទេះគ្រប់ប្រភេទ ដែលអូសដោយកំលាំងគោ-ក្របី ។

**៤៥. ចំនួនកង់** : គឺជាកង់គ្រប់ប្រភេទដែលប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរ។ គិតទាំងកង់អូសរឺម៉កផងដែរ។

**៤៦. ចំនួនទូកចែវ/អុំ** : គឺជាប្រភេទទូកដែលប្រើចែវ ឬ ច្រវ៉ា សំរាប់ជាមធ្យោបាយដឹកជញ្ជូនផ្លូវទឹកសំរាប់នេសាទ ឬ ចំលងអ្នកដំណើរក្នុងរង្វង់ទិជិតៗ ។

៤៧. **ចំនួនទូកម៉ាស៊ីនកាណូត** : ចំនួនទូកប្រើប្រាស់រុញដោយកំលាំងម៉ាស៊ីនតូចឬធំ ឬ ជាកាណូត សណ្តោង ។

៤៨. **ចំងាយពីភូមិទៅផ្សារដែលនៅជិតបំផុតគិតជាគីឡូម៉ែត្រ** : គឺជាចំងាយគិតពីចំណុចកណ្តាល ភូមិ ទៅទីផ្សារដែលមានសកម្មភាពពីព្រលឹមដល់ព្រលប់ជារៀងរាល់ថ្ងៃ ឬមានសកម្មភាពរយៈ ពេលពី៦ម៉ោងទៅ៨ម៉ោង។ គិតជាគីឡូម៉ែត្រ។ បើផ្សារមានទីតាំងនៅក្នុងភូមិចំងាយគឺសូន្យ គីឡូម៉ែត្រ។

៤៩. **ចំងាយពីភូមិទៅផ្លូវដែលនៅជិតបំផុតដែលអាចបើកឡានចេញចូលពេញមួយឆ្នាំ** : គឺ ចំងាយពីភូមិទៅផ្លូវដែលឡានអាចបើកចេញចូលបានពេញមួយឆ្នាំ។ គិតជាគីឡូម៉ែត្រ។ បើភូមិ នៅជាប់ផ្លូវតែម្តង ចំងាយគឺសូន្យគីឡូម៉ែត្រ។

៥០. **ចំងាយពីភូមិទៅសាលាមធ្យមសិក្សាជិតបំផុត (គិតជាគម)** : គឺជាចំងាយគិតពីចំណុច កណ្តាលភូមិទៅដល់សាលាមធ្យមសិក្សានៅជិតបំផុត គិតជាគីឡូម៉ែត្រ។ បើសាលាមធ្យមសិក្សា មានទីតាំងនៅក្នុងភូមិចំងាយគឺសូន្យគីឡូម៉ែត្រ ។

៥១. **ចំងាយពីភូមិទៅមណ្ឌលសុខភាពឃុំនៅជិតបំផុត** : ជាចំងាយធ្វើដំណើរគិតពីចំណុចកណ្តាលភូមិ ទៅដល់មណ្ឌលសុខភាពឃុំ ដែលនៅជិតបំផុត គិតជាគីឡូម៉ែត្រ។ ប្រសិនបើមណ្ឌលសុខភាពឃុំ នៅក្នុងភូមិ ត្រូវគិតជាចំងាយសូន្យគីឡូម៉ែត្រ។

៥២. **ផ្ទៃដីស្រែវស្សា** : គឺជាផ្ទៃដីស្រែវស្សា ដែលពឹងផ្អែកលើតែទឹកភ្លៀង ដោយគ្មានប្រព័ន្ធស្រោចស្រព ធារាសាស្ត្រ ឬ អណ្តូងកសិកម្ម ហើយធ្វើបានម្តងក្នុង១ឆ្នាំ គិតជាហិកតា។

៥៣. **ផ្ទៃដីស្រែវស្សាបន្ថែនរដូវ** : គឺជាផ្ទៃដីស្រែវស្សាដែលពឹងផ្អែកលើទឹកភ្លៀង គ្មានប្រព័ន្ធស្រោចស្រព ធារាស្ត្រ ឬអណ្តូងកសិកម្ម តែធ្វើបានលើសពីមួយដងក្នុងមួយឆ្នាំ គិតជាហិកតា។

៥៤. **ផ្ទៃដីស្រែប្រាំងស្រោចស្រព** : ជាផ្ទៃដីស្រែប្រាំងដែលមានប្រព័ន្ធស្រោចស្រព ឬ អណ្តូងកសិកម្ម ដែលអាចបង្កើតរដូវគិតជាហិកតា។

**៥៥. ផ្ទៃដីស្រែប្រាំងប្រដេញទឹក** : ជាផ្ទៃដីស្រែដែលធ្វើប្រដេញតាមទឹកស្រកទៅវិញនៅរដូវប្រាំង គិតជាហិកតា ។

**៥៦. ផ្ទៃដីស្រូវចំការគិតជាហិកតា** : គឺជាផ្ទៃដីដែលប្រជាជនធ្វើស្រូវ តាមបច្ចេកទេសដាំស្រូវចំការ គិត ជាហិកតា ។

**៥៧. ផ្ទៃដីដាំដុះផ្សេងៗទៀត** : ជាផ្ទៃដីសំរាប់ដាំដំណាំគ្រប់ប្រភេទដូចជា ពោត សណ្តែក ល្ង និងដំណាំចំការផ្សេងទៀត គិតជាហិកតា.......... ។ល ។

**៥៨. ផ្ទៃដីមានមីនគិតជាហិកតា** : ជាផ្ទៃដីដែលមានបង្កប់គ្រាប់មីនគ្រប់ប្រភេទមាននៅក្នុងភូមិ គិតជាហិកតា ។

**សំគាល់** : រាល់ទំហំដីទាំងអស់ត្រូវគិតជាហិកតាដូចគ្នា ។ ទោះជានៅតំបន់ខ្លះ គេនិយមប្រើជាអារ ឬ ...... ក៏ដោយ ស្ថិតិត្រូវគិតជាខ្នាតហិកតាអោយរួចទើបចុះទៅក្នុងបញ្ជី ។

**៥៩. ចំនួនអណ្តូងទឹកស្រោចស្រព** : គឺជាអណ្តូងទឹកដែលមានប្រភពពីធម្មជាតិ ឬ អណ្តូងកសិកម្មដែលមានប្រភពទឹកស្រោចស្រពមិនចេះរីងស្ងួត ។

## ជំពូក ៨ : ផលិតផលក្នុងឆ្នាំ

**៦០. ផលិតផលស្រូវសរុបក្នុងរយៈពេល ១២ខែកន្លងមកគិតជាតោន** : គឺជាផលិតផលស្រូវសរុបទាំងអស់ ដែលអ្នកភូមិផលិតបានក្នុងរយៈពេល ១២ខែក្នុងកន្លងមក ។

**៦១. ផលិតផលពោតសរុបក្នុងរយៈពេល ១២ខែកន្លងមក គិតជាតោន** : គឺជាផលិតផលពោតគ្រប់ ប្រភេទសរុបទាំងអស់ ដែលអ្នកភូមិផលិតបានក្នុងរយៈពេល ១២ខែកន្លងមក ។

**៦២. ចំនួនគោក្របីដែលមិនមែនជាកំលាំងអូសទាញមានក្នុងភូមិ** : គឺជាចំនួនគោក្របីដែលមិនប្រើប្រាស់ជាកំលាំងអូសទាញ ដែលមាននៅក្នុងភូមិ ហើយមិនបានប្រើប្រាស់ជាកំលាំងអូសទាញឡើយ ។

**៦៣. ចំនួនគោក្របីដែលជាកំលាំងអូសទាញមានក្នុងភូមិ** : គឺជាចំនួនគោក្របី ដែលប្រើប្រាស់ជាកំលាំងអូសទាញ ដែលមាននៅក្នុងភូមិ ។

**៦៤. ចំនួនជ្រូកនៅក្នុងភូមិ** : គឺជាចំនួនជ្រូកដែលប្រជាជនចិញ្ចឹមសំរាប់យកសាច់ ឬ លក់និងយកកូនលក់ មាននៅក្នុងភូមិ ។

**៦៥. ចំនួនភ្នាក់ងារពេទ្យសត្វនៅក្នុងភូមិ** : ជាភ្នាក់ងារល្អ ឬ ជនស្ម័គ្រចិត្តក្នុងភូមិ ដែលបានបណ្តុះបណ្តាលដោយមន្ទីរកសិកម្មខេត្ត-ក្រុង ។

[illegible]

**៦៦. ចំនួនកន្លែងផ្តល់សេវាកម្មកសិកម្ម** : ទីកន្លែងដែលលក់ ទិញ ឬ ផ្តល់សេវាកម្មកសិកម្មទាក់ទងទៅនិងស្រូវពូជបន្លែ ជី ឧបករណ៍-សំភារៈកសិកម្ម វ៉ាក់សាំង ថ្នាំសំលាប់សត្វល្អិត កូនត្រីជាដើម............ ។ល។ (រាប់ចំនួនធ្វើអាជីវកម្មក្នុងផ្នែកនេះក្នុងឆ្នាំ) ។

**៦៧. ចំនួនកន្លែងផលិតកម្មកសិកម្ម** : ជាចំនួនទីកន្លែងដែលចិញ្ចឹមត្រី កង្កែប ទា មាន់ ឬ កសិដ្ឋានផ្សេងៗ........ ។ល។ (ដែលមិនមែនសំរាប់បរិភោគក្នុងគ្រួសារនោះទេ ប៉ុន្តែសំរាប់សជាចំណូលក្នុងគ្រួសារ) រាប់ចំនួនធ្វើអាជីវកម្មជាក់ស្តែងក្នុងឆ្នាំ ។

**៦៨. កន្លែងផលិតកម្មសិប្បកម្មជនបទ** : ចំនួនអាជីវកម្មដែលបានដំណើរការផលិតផលក្នុងស្រុកផ្សេងៗ ដូចជា ទីកន្លែងធ្វើស្ករត្នោត បិទស្រា ធ្វើទឹកកក ផលិតធ្យូង ជាងដែក ធ្វើទ្វារ បង្អួច ធ្វើនំប៉័ង កន្លែង ធ្វើធូប កន្លែងធ្វើឆ្នាំង/ក្អម/ថូ កន្លែងធ្វើចង្ក្រាន កន្លែងធ្វើពាងទឹក កន្លែងធ្វើប្រហុក/ផ្អក/មាំ...... ។ល។ រាប់ចំនួនអាជីវកម្មជាក់ស្តែងក្នុងឆ្នាំ ។

**៦៩. ចំនួនសេវាកម្មនិងតូបលក់ទំនិញនានា** : តូបផ្តល់សេវាផ្សេងៗនៅក្នុងភូមិ ដូចជាតូបកាត់សក់ អ៊ុតសក់ ជាងកាត់ដេរ ភោជនីយដ្ឋាន តូបលក់ចំណីអាហារ/ គ្រឿងទេស កន្លែងថតរូប លក់ថ្នាំ ពេទ្យ រោងជាងជួសជុលម៉ូតូ/កង់ ម៉ាស៊ីនចលករ ម៉ាញេ ទូរទស្សន៍ បញ្ចូលអាគុយ សំអាងការ កន្លែងបញ្ចាំងវីដេអូ / ការ៉ាអូឃេ....... ។ល។

**សំគាល់** : ប្រសិនបើមានអ្នកធ្វើអាជីវកម្មណាមួយដែលត្រូវគ្នា និងរាល់សំណួរទាំងបួន សូមកត់ត្រាតែមួយបានហើយ ដោយរាប់បញ្ចូលទៅផ្នែកណាមួយ ដែលសំខាន់ជាងគេ នៅក្នុងអាជីវកម្មចំរុះរបស់ គាត់.

## ជំពូក ១១ : ទ្រព្យសម្បត្តិគ្រួសារ

**៧០. ចំនួនទូរទស្សន៍** : ជាទូរទស្សន៍គ្រប់ប្រភេទដែលកំពុងប្រើប្រាស់ក្នុងភូមិ ។

## ជំពូក ១២ : ការចាកចេញពីភូមិទៅរកការធ្វើ

**៧១. ចំនួនមនុស្សស្រីដែលចាកចេញពីភូមិទៅរកការធ្វើ** : ជាការចាកចេញរបស់មនុស្សស្រី ដើម្បីរកការងារធ្វើនៅខាងក្រៅភូមិរបស់ខ្លួនក្នុងរយៈពេលខ្លី ហើយមេភូមិនៅតែទទួលស្គាល់ថាជាប្រជាជននៅក្នុងភូមិរបស់គាត់។ អ្នកទៅបំរើការងារជាអចិន្ត្រៃយ៍ជាមួយក្រុមហ៊ុន ឬ អង្គការផ្សេងៗនៅភូមិ ចាប់ពី ៣ខែឡើងទៅ ហើយមេភូមិឈប់ទទួលស្គាល់ថាជាប្រជាជននៅក្នុងភូមិរបស់គាត់ គឺមិនត្រូវបានរាប់បញ្ចូលថាជាអ្នកចាកចេញទៅរកការងារធ្វើទេ។

**៧២. ចំនួនមនុស្សប្រុសដែលចាកចេញពីភូមិទៅរកការធ្វើ** : ដូចសំណួរ ៧១ (គ្រាន់តែប្តូរពីស្រីទៅប្រុស) ។

## ជំពូក ១៣ : ការរៀបចំតាមសហគមន៍ជនបទ

**៧៣. ចំនួនក្រុមឥណទានសាច់ប្រាក់** : ជាក្រុមដែលបានបង្កើតឡើងដោយអ្នកភូមិ ឬ អង្គការ ឬស្ថាប័នរដ្ឋ ដើម្បីសន្សំ និងខ្ចីប្រាក់ ។

**៧៤. ចំនួនក្រុមធនាគារសត្វ** : ជាក្រុមធនាគារសត្វដែលបានបង្កើតឡើង ដោយអ្នកភូមិ ឬ អង្គការនានា ឬស្ថាប័នរដ្ឋ ដូចជា ធនាគារជ្រូក ធនាគារគោក្របី ។ល.

**៧៥. ចំនួនក្រុមធនាគារស្រូវ** : ជាក្រុមធនាគារស្រូវដែលបានបង្កើតឡើងដោយអ្នកភូមិ ឬ អង្គការនានា ឬ ស្ថាប័នរដ្ឋ។ ធនាគារនេះអាចជាធនាគារស្រូវពូជ ឬ ស្រូវសំរាប់ហូប ។

**៧៦. ចំនួនក្រុមប្រើប្រាស់ទឹកហូប** : ជាចំនួនក្រុមដែលប្រើប្រាស់ទឹកហូបបង្កើតឡើងដោយភាគច្រើនជាប្រជាជនក្នុងភូមិ ដែលមានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល។ ឧទាហរណ៍ : នៅក្នុង ភូមិ (ក) មានពីរគ្រួសារមានអណ្តូងទឹកសំរាប់ប្រើប្រាស់ខ្លួនឯងតែដប់គ្រួសារទៀតគ្មានអណ្តូងទឹកប្រើប្រាស់ ដូច្នេះអង្គការនោះជួយជីកអណ្តូងមួយអោយប្រជាជនដប់គ្រួសារនោះ ។ ដើម្បីអោយទឹកអណ្តូងមាននអនាម័យប្រជាជនបានបង្កើតជាក្រុមដើម្បីរក្សាអណ្តូងនោះ ។

**៧៧. ចំនួនក្រុមកសិករប្រើប្រាស់ទឹកស្រោចស្រព** : គឺជាក្រុមដែលបង្កើតឡើងដោយប្រជាជន ក្នុងការប្រើប្រាស់ទឹកស្រោចស្រព។ ឧទាហរណ៍ : ប្រព័ន្ធធារាសាស្ត្រមួយមានប្រភពពីទឹកទន្លេដោយហូរកាត់ភូមិ (ក) ភូមិ(ខ) និងភូមិ(គ) ដូចនេះ ដើម្បីអោយមានប្រភពទឹកគ្រប់គ្រាន់ គាត់បានបង្កើត

ជាក្រុមកសិករដោយមានតំណាងពីភូមិទាំងបី ដើម្បីថែរក្សាម៉ាស៊ីនបូមទឹក និងដើម្បីធ្វើអន្តរាគមន៍នៅពេលដែលមានភាពរាំងស្ងួត ។

ចូរសំគាល់ថា សហគមណ៍ជនបទ គឺជាក្រុមធ្វើសកម្មភាពដែលមានសមាជិកភាគច្រើនជាប្រជាជនក្នុងភូមិ សំរាប់បំរើ ឬ ការពារប្រយោជណ៍អោយអ្នកភូមិ ។

≈≈≈≈

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ១៥២ កធសសរ

* * *

## រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត នៃនិកាយ " **ប្រេស្ទ្រីន** " នៅខេត្តកំពង់ធំ របស់លោក **គង់ សំអឿន** អាយុ ៥៨ឆ្នាំ . ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១

យោងចំណារឯកភាពរបស់សាលាខេត្តកំពង់ លេខ ៩៣បជ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រិស្ត ឈ្មោះ " **ប្រេស្ទ្រីនបាជ័យ** " មួយ កន្លែងដែលមានទីតាំងស្ថិតនៅក្រុមទី១២ ភូមិបាជ័យ ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។